គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

API BUILDING CAPACITY FOR CHANGE

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

CHRAC

# សេចក្តីព្រាងឯកសារទស្សនទាន

# យុទ្ធសាស្ត្រតស៊ូមតិរួមសម្រាប់លើកកម្ពស់បរិយាកាសអំណោយផលក្នុងប្រទេសកម្ពុជា

## ICF/KSSA ៖ រាជធានីភ្នំពេញ

## ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៤

### ១. សេចក្តីផ្តើម

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាធ្វើការសម្រេចឱ្យបានឆាប់រហ័សនូវការអនុម័តច្បាប់ជាច្រើន រួមមាន ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីឧក្រិដ្ឋកម្មទាក់ទងនឹងការប្រើប្រាស់កុំព្យូទ័រ ឬ អ៊ីនធើរណែត ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ ច្បាប់ស្តីពីឧត្តមប្រឹក្សាអង្គចៅក្រម ច្បាប់ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម និងច្បាប់ស្តីពីសហជីព ។ល។ ការអនុម័តច្បាប់ទាំងនេះត្រូវបានពិនិត្យមើលក្នុងដំណាក់កាលខុសៗគ្នា។ ច្បាប់មួយចំនួនត្រូវបានរៀបចំជាសេចក្តីព្រាងរួចរាល់ និងបានប្រឹក្សាជាមួយក្រុមភាគីពាក់ព័ន្ធជាច្រើន រួមទាំង អ្នកជំនាញមកពីសង្គមស៊ីវិល វិស័យឯកជន អ្នកជំនាញច្បាប់ និងអ្នកជំនាញខាងអប់រំ ដើម្បីធានានូវតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល ខណៈពេលច្បាប់មួយចំនួនទៀតត្រូវបានបញ្ជូនទៅកាន់រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីស្នើសុំការឯកភាពដោយមិនមានការបើកចំហសម្រាប់ការប្រឹក្សាជាសាធារណៈ។ លើសពីនេះ ការវិភាគត្រូវបានធ្វើឡើងមកពីប្រភពខុសៗគ្នា ដូចជា អ្នកវិភាគឯករាជ្យ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ និងការវិភាគមួយចំនួនទៀតត្រូវបានរៀបចំឡើងសម្រាប់តែលើច្បាប់ជាអាទិភាពមួយចំនួនប៉ុណ្ណោះ ដែលគេជឿជាក់ថា វាមានងាយមានផលប៉ះពាល់ខ្លាំងលើផលប្រយោជន៍ លទ្ធិប្រជាធិបតេយ្យ បរិយាកាសអំណោយផល និងសិទ្ធិរបស់ប្រជាជនកម្ពុជា។

បើយើងក្រឡេកមើលបទពិសោធន៍របស់សង្គមស៊ីវិលបានអនុវត្តកន្លងមក វិធីសាស្ត្របំពេញការងាររបស់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ជាញឹកញាប់ ត្រូវបានយល់ឃើញថា ជាការប្រកួតប្រជែងជាជាងកិច្ចសហប្រតិបត្តិការ និងការគាំទ្រគ្នាទៅវិញទៅមក។ លើសពីនេះ ការបន្តអនុវត្តការងារដែលជាទំលាប់ចាស់របស់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាអាចធ្វើឱ្យអង្គការសង្គមស៊ីវិលនីមួយៗងាយទទួលរងឥទ្ធិពល និងពឹងផ្អែកលើរដ្ឋាភិបាល និង/ឬ ដៃគូអភិវឌ្ឍន៍ ដែលអាចបណ្តាលឱ្យមានការបែកបាក់និងទន់ខ្សោយក្នុងពេលអនាគត។ កត្តានេះអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាព និងការត្រៀមខ្លួនរបស់អង្គការសង្គមស៊ីវិលក្នុងក្លាយខ្លួនជាដៃគូអភិវឌ្ឍន៍មួយដែលមានប្រសិទ្ធភាព។មានការផ្តល់ជាអនុសាសន៍ជាច្រើនថា វាកាន់តែមានប្រសិទ្ធភាពខ្លាំង ប្រសិនបើអង្គការសង្គមស៊ីវិលគ្រប់ប្រភេទទាំងអស់អាចសហការគ្នាបង្កើតទស្សនវិស័យរួមជាយុទ្ធសាស្ត្រក្នុងការកំណត់ទិសដៅជាក់លាក់ តួនាទីច្បាស់លាស់ និងចំណុចផ្តោតចិត្តទុកដាក់គោលសម្រាប់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ដើម្បីឱ្យអង្គការទាំងនេះអាចរៀបចំបានកាន់តែប្រសើរ និងមានភាពចុះសម្រុងគ្នាកាន់តែខ្លាំងក្នុងការឆ្លើយតបតាមនិន្នាការអភិវឌ្ឍន៍ជាតិ និងពិភពលោក។ សាមគ្គីភាព និងសុខុដុមនីយកម្មក្នុងចំណោមអង្គការសង្គមស៊ីវិលចាំបាច់ត្រូវពង្រឹងក្នុងពេលជាមួយគ្នា ដើម្បីអាចឱ្យពួកគេមានសិទ្ធិរឹងមាំមួយក្នុងការតស៊ូមតិជាមួយបញ្ហាដែលបញ្ចូលគ្នាក្នុងប្រទេសកម្ពុជា ជាពិសេស បញ្ហាពាក់ព័ន្ធនឹងការបង្កើតច្បាប់/បទប្បញ្ញត្តិ/គោលនយោបាយ។

នាពេលថ្មីៗនេះ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលជាច្រើនបានធ្វើកិច្ចពិភាក្សាជាច្រើនក្នុងការឆ្លើយតបនឹងបរិបទថ្មីៗនៃការអភិវឌ្ឍប្រទេសកម្ពុជា ជាពិសេស ពាក់ព័ន្ធនឹងការបង្កើតច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយ ដោយសារតែបញ្ហានេះមានផលប៉ះពាល់ខ្លាំងលើបរិយាកាសអំណោយផល ឬ អង្គការសង្គមស៊ីវិលក្នុងការរៀបចំក្នុងប្រទេសកម្ពុជា។ អង្គការសង្គមស៊ីវិលបានព្រមព្រៀងគ្នាក្នុងការកំណត់អាទិភាព និងចាត់វិធានការរួមលើសេចក្តីព្រាងច្បាប់ចំនួនប្រាំពីរ រួមមាន ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីឧក្រិដ្ឋកម្មទាក់ទងនឹងការប្រើប្រាស់កុំព្យូទ័រ ឬ អ៊ីនធើរណែត ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ ច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ច្បាប់ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម និងច្បាប់ស្តីពីសហជីព។ លទ្ធផលសំខាន់ៗដែលទទួលបានពីកិច្ចពិភាក្សាទាំងនេះ គឺជាការរួមបញ្ចូលគ្នានៃការវិភាគដែលមានទាំងអស់លើច្បាប់ថ្មីៗដូចលើកឡើងខាងលើ ដើម្បីបង្កើតយុទ្ធសាស្ត្រតស៊ូមតិរួមសម្រាប់ជំរុញការអភិវឌ្ឍភាពជាដៃគូដែលមានទស្សនវិស័យ និងប្រកបដោយអត្ថន័យ។ ការចងក្រងការវិភាគដែលមានទាំងអស់លើច្បាប់ទាំងនេះ ត្រូវបានបែងចែកផ្អែកតាមលក្ខន្តិកៈរួមដូចតទៅ ៖ អាទិភាព អត្ថប្រយោជន៍ ផលវិបាក និងផលប៉ះពាល់នៃច្បាប់ទាំងនេះលើសិទ្ធិ និងសេរីភាពរបស់ប្រជាជនកម្ពុជា ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញជាតិនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះ សង្គមស៊ីវិលនៅតែចាំបាច់ត្រូវសហការគ្នាក្នុងទ្រង់ទ្រាយធំ ដើម្បីផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ពិភាក្សាគ្នា និងឯកភាពលើយុទ្ធសាស្ត្រតស៊ូមតិរួម ដែលអង្គការសង្គមស៊ីវិលអាចប្រើប្រាស់សម្រាប់តស៊ូមតិក្នុងការលើកកម្ពស់បរិយាកាសអំណោយផលក្នុងប្រទេសកម្ពុជា។

យោងតាមបរិបទលើកឡើងខាងលើ អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាមានគម្រោងរៀបចំកិច្ចសន្ទនាស្តីពី "**យុទ្ធសាស្ត្រតស៊ូមតិរួមដើម្បីលើកកម្ពស់បរិយាកាសអំណោយផលក្នុងប្រទេសកម្ពុជា**" ដែលនឹងរៀបចំឡើងនៅ**ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤** នៅរាជធានីភ្នំពេញ ដើម្បីផ្តល់ជូនជាពិសេសដល់អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀតនូវ ៖ ១) ព័ត៌មាន និងការវិភាគថ្មីៗបំផុតអំពីច្បាប់ដែលនឹងដាក់អនុម័តនាពេលខាងមុខនេះ និង២) ការបង្កើតយុទ្ធសាស្ត្រតស៊ូមតិរួមសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងច្បាប់ទាំងនេះ។ តាមការរំពឹងទុក នៅពេលការវិភាគដែលរួមបញ្ចូលគ្នា និងយុទ្ធសាស្ត្រតស៊ូមតិត្រូវបានរៀបចំរួច ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស អង្គការសង្គមស៊ីវិល មានលទ្ធភាពប្រើសាររួម និងធ្វើយុទ្ធនាការតស៊ូមតិផ្អែកតាមគោលដៅ និងវិធីសាស្ត្ររបស់ពួកគេក្នុងការជំរុញឱ្យមានបរិយាកាសកាន់តែមានអំណោយផលក្នុងប្រទេសកម្ពុជា។

**២. គោលដៅ**

១. ដើម្បីចែករំលែកការវិភាគ និងបញ្ហាកង្វល់ទាក់ទងនឹងសេចក្តីព្រាងច្បាប់ទាំងប្រាំពីរ
២. ដើម្បីពិភាក្សា និងប្រមូលព័ត៌មានសម្រាប់កិច្ចប្រឹងប្រែងតស៊ូមតិរួមលើច្បាប់ទាំងនេះ
៣. ដើម្បីកំណត់សកម្មភាពអាទិភាពសម្រាប់អនុវត្តផែនការតស៊ូមតិ
៤. ដើម្បីពិភាក្សា និងបញ្ចូលសេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិលបញ្ចូលគ្នាទាក់ទងនឹងសេចក្តីព្រាងច្បាប់ថ្មីៗនេះ

**៣. លទ្ធផលដែលអាចសម្រេចបាន**

១. មានអ្នកចូលរួមយ៉ាងតិចចំនួន១៥០-២០០នាក់មកពីអង្គការសង្គមស៊ីវិលគ្រប់ប្រភេទ ដែលទទួលបានព័ត៌មានអំពីគំនិតសំខាន់ៗនៃសេចក្តីព្រាងច្បាប់ទាំងនេះ និងការត្រៀមខ្លួនចូលរួមក្នុងកិច្ចប្រឹងប្រែងតស៊ូមតិរួម
២. បណ្តុំយុទ្ធសាស្ត្រតស៊ូមតិដែលបានកំណត់ និងឯកភាពជាគោលការណ៍
៣. សកម្មភាពអាទិភាពរយៈពេលខ្លី និងមធ្យោបាយសម្រាប់អនុវត្តសកម្មភាពទាំងនោះ ដែលបានកំណត់ និងឯកភាព និង
៤. សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល ដែលបានសម្រេចចុងក្រោយ និងចែក រំលែកជាសាធារណៈ។

**៤. អ្នកចូលរួម ៖**

តាមការរំពឹងទុក អ្នកចូលរួមក្នុងសិក្ខាសាលានេះ មានចំនួនប្រហែល១៥០-២០០នាក់ ដែលមកពីអង្គការមិនមែនរដ្ឋាភិបាល សមាគម អង្គការតាមសហគមន៍ តំណាងបណ្តាញអង្គការមិនមែនរដ្ឋាភិបាលតាមខេត្ត ក្រុមក្រៅបប្រព័ន្ធ និងប្រជាជនតាមមូលដ្ឋាន។ វាគ្មិន/អ្នកជំនាញមកពីតំណាងអង្គការសង្គមស៊ីវិល អ្នកច្បាប់ និងអ្នកប្រឹក្សាឯករាជ្យ ដែលមានចំណេះដឹង និងការការយល់ដឹងខ្ពស់អំពីបញ្ហាខាងលើនឹងទទួលបានការអញ្ជើញឱ្យចូលរួមជាកិត្តិយស។

**៥. របៀបវារៈ**

| ពេលវេលា | វគ្គ | អ្នកសម្របសម្រួល |
|---|---|---|
| ៧:៣០-៨:០០ព្រឹក | ការចុះឈ្មោះ | អង្គការ CCC, API និង TIC |
| ៨:០០-៨:០៥ ព្រឹក | **សេចក្តីផ្តើម ៖**<br>- គោរពភ្លេងជាតិ<br>- គោលបំណង និងគោលដៅនៃសិក្ខាសាលា | **លោក មី ណាក់**<br>អ្នកជំនាញតស៊ូមតិរបស់អង្គការ CCC |
| ៨:០៥-៨:១៥ ព្រឹក | **កិច្ចស្វាគមន៍ និងពិធីបើក**<br>សន្ទរកថាស្វាគមន៍ និងបើក | **លោក សៀង សារឿន**<br>នាយកប្រតិបត្តិនៃអង្គការ CCC |
| ៨:១៥-១០:០០ ព្រឹក | **វគ្គ១ ៖ បទបង្ហាញអំពីលទ្ធផលរកឃើញសំខាន់ៗនៃសេចក្តីព្រាងច្បាប់**<br>- បញ្ហាកង្វល់សំខាន់ៗនៃសេចក្តីព្រាងច្បាប់ចំនួនបីទាក់ទងនឹងតុលាការ និងអង្គចៅក្រម<br>- បញ្ហាកង្វល់សំខាន់ៗនៃសេចក្តីព្រាងច្បាប់ស្តីពីសហជីព<br>- បញ្ហាកង្វល់សំខាន់ៗនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម<br>- បញ្ហាកង្វល់សំខាន់ៗនៃសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីឧក្រិដ្ឋកម្មទាក់ទងនឹងការប្រើប្រាស់កុំព្យូទ័រ ឬ អ៊ីនធើរណែត<br>សំណួរ និងចម្លើយ | អ្នកសម្របសម្រួល<br>**លោក សួន ប៊ុនស័ក្តិ**<br>ប្រធានលេខាធិការដ្ឋាន CHRAC<br>**លោក ឌុច ពិសិដ្ឋ**<br>អ្នកសម្របសម្រួលគម្រោងរបស់អង្គការ CCHR<br>**លោក មឿន តុលា**<br>ប្រធានកម្មវិធីនៃអង្គការ CLEC<br>**លោក ថេង សារឿន**<br>អ្នកសម្របសម្រួលអង្គការ CCFC<br>**លោក Andrew Boname**<br>ប្រធានក្រុមការងារនៃអង្គការ EWMI |

| ពេលវេលា | វគ្គ | អ្នកសម្របសម្រួល |
|---|---|---|
| ១០:០០-១០:២០ព្រឹក | សម្រាកទទួលទានអាហារសម្រន់ | អ្នកចូលរួមទាំងអស់ |
| ១០:២០-១២:០០ រសៀល | **វគ្គ២ ៖ បទបង្ហាញអំពីសេចក្តីព្រាងនៃសេចក្តីថ្លែងការណ៍រួម និងស្វែងរកមតិយោបល់ពីអ្នកចូលរួម ដើម្បីរៀបចំបញ្ចប់សេចក្តីថ្លែងការណ៍** | **លោក សឿង សារឿន**<br>នាយកប្រតិបត្តិនៃអង្គការ CCC |
| ១៣:៣០-១៤:១៥ រសៀល | **វគ្គ៣ ៖ ផែនទីចង្អុលផ្លូវ និងយុទ្ធសាស្រ្តតស៊ូមតិ**<br>បទបង្ហាញអំពីសេចក្តីព្រាងនៃផែនទីចង្អុលផ្លូវ និងយុទ្ធសាស្រ្តតស៊ូមតិ | **លោក ឡាម សុជាតិ**<br>នាយករងនៃអង្គការ API |
| ១៤:១៥-១៥:១៥ រសៀល | **វគ្គ៤ ៖ ការពិភាក្សាជាក្រុម**<br>អ្នកចូលរួមនឹងត្រូវបានបែងចែកជាក្រុមតូចៗ ដើម្បីកំណត់ផែនការសកម្មភាពយុទ្ធសាស្រ្តឱ្យកាន់តែលម្អិត | **អ្នកចូលរួម ៖**<br>**លោក សេក បរិសុទ្ធ**<br>ទីប្រឹក្សានៃអង្គការ API<br>**លោក ប៉ែន រក្សា**<br>ប្រធានកម្មវិធីនៃអង្គការ TIC |
| ១៥:១៥-១៥:៣០ រសៀល | សម្រាកទទួលទានអាហារសម្រន់ | អ្នកចូលរួមទាំងអស់ |
| ១៥:៣០-១៦:៣០ រសៀល | **វគ្គ៥ ៖ សេចក្តីសន្និដ្ឋានរបស់ក្រុមពិភាក្សា**<br>តំណាងមួយរូបមកពីក្រុមនីមួយៗនឹងត្រូវឡើងមកចែករំលែករបាយការណ៍ខ្លីរបស់ក្រុមខ្លួនទាក់ទងនឹងប្រធានបទនីមួយៗជូនអង្គសិក្ខាសាលា | **តំណាងក្រុមនីមួយៗ** |
| ១៦:៣០-១៦:៤៥ រសៀល | **វគ្គ៦ ៖** សេចក្តីសន្និដ្ឋាន និងសន្ទរកថាបិទ | **លោក ពេជ្រ ពិសី**<br>នាយកកម្មវិធីនៃអង្គការ TIC |